**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

# អូស្ត្រាលីអបអរពីភាពចម្រុះនិងបរិយាបន្នរបស់ខ្លួន

កាលពីយប់មិញនេះ ឯកអគ្គរដ្ឋទូតអូស្ត្រាលី ចាស្ទីន វ៉ាយអេត បានទទួលស្វាគមន៍ភ្ញៀវកិត្តិយស ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សាយ សំអាល់ និងបណ្តាភ្ញៀវមកពីខាងរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នការទូត ក្នុងពិធីបុណ្យជាតិអូស្ត្រាលីរបស់ស្ថានទូត។

ទិវាបុណ្យជាតិអូស្ត្រាលី ជាឱកាសមួយសម្រាប់ប្រជាជនអូស្ត្រាលី ដើម្បីអបអរភាពជោគជ័យ និងឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ និងរឿងរ៉ាវរបស់ប្រទេស រួមទាំងប្រវត្តិសាស្ត្ររបស់ជនជាតិដើមដំបូង ដែលមានតាំងពីជាង ៦០ ០០០ ឆ្នាំ មកហើយ ដែលបានបន្តមកដល់ សង្គមទំនើប ចម្រុះជាតិសាសន៍ អូស្ត្រាលីសព្វថ្ងៃនេះ។

ទិវាបុណ្យជាតិអូស្ត្រាលី ក៏ជាពេលវេលាមួយ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមិត្តភ័ក្តិ និងបង្កើតទំនាក់ទំនងថ្មីផងដែរ។

ឯកអគ្គរដ្ឋទូត វ៉ាយអេត បានមានប្រសាសន៍ថា "ប្រទេសអូស្ត្រាលី និងប្រទេសកម្ពុជា ភ្ជាប់ទំនាក់ទំនងគ្នាក្នុងវិស័យជាច្រើន។ ភាពជាដៃគូរបស់យើង បានចាក់ឫសទៅក្នុងប្រវត្តិសាស្ត្ររបស់យើង ពង្រឹងដោយទំនាក់ទំនងយ៉ាងស៊ីជម្រៅរវាងប្រជាជនរបស់យើង ព្រមទាំងកិច្ចសហប្រតិបត្តិការរបស់យើង ដែលកំពុងតែពង្រីកឡើងដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ"។

ឯកអគ្គរដ្ឋទូត វ៉ាយអេត បានបន្ថែមថា "ទំនាក់ទំនងរបស់យើងមានលើវិស័យជាច្រើន។ យើងសហការក្នុងវិស័យសុខាភិបាល ការអប់រំ កសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ច ថាមពល និងអាកាសធាតុ ការការពារសង្គម និងសន្តិសុខជាតិ សង្គមស៊ីវិល លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស"។

"យើងក៏កំពុងស្វែងរកផលប្រយោជន៍រួមក្នុងតំបន់តាមរយៈអាស៊ានផងដែរ"។

ឆ្នាំនេះ អាស៊ាន និងប្រទេសអូស្ត្រាលីប្រារព្ធខួប ៥០ឆ្នាំ នៃភាពជាដៃគូសន្ទនា។ ប្រទេសអូស្ត្រាលីរង់ចាំទទួលស្វាគមន៍ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំអាស៊ាន និងទីម័រខាងកើត ក្នុងកិច្ចប្រជុំកំពូលពិសេស នៅខែមីនាខាងមុខនេះ ដើម្បីអបអរខួប ៥០ឆ្នាំ នៃទំនាក់ទំនងរវាងអាស៊ាន-អូស្ត្រាលី។

ក្នុងនាមជាដៃគូសន្ទនាដំបូងរបស់អាស៊ាន និងជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ប្រទេសអូស្ត្រាលីប្តេជ្ញាយ៉ាងមុតមាំចំពោះភាពជាមជ្ឈភាពអាស៊ាន និងទស្សនវិស័យអាស៊ានស្តីពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ ប្រទេសអូស្ត្រាលីមើលឃើញថា អាស៊ានគឺជាចំណុចស្នូលនៃតំបន់ដែលមានស្ថិរភាព សន្តិភាព វិបុលភាព និងសន្តិសុខ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au